PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## សម្រាប់ត្រីមាសទីបួន នៃឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់

## នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២

PESTECH

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទីបួន ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) | ឆ្នាំ ២០២០ (លានរៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ២០២ ២៨២ | ១ ១៦៦ ៨៨២ | ១ ០១៦ ១១២ |
| បំណុលសរុប | | ១ ០៩២ ២៦៦ | ១ ០៧២ ៩៨៥ | ៩៤៦ ១៥៥ |
| មូលធនសរុប | | ១១០ ០១៦ | ៩៣ ៨៩៧ | ៦៩ ៩៥៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទីបួន ឆ្នាំ ២០២២ (លានរៀល)** | **ត្រីមាសទីបួន ឆ្នាំ ២០២១ (លានរៀល)** | **ត្រីមាសទីបួន ឆ្នាំ ២០២០ (លានរៀល)** |
| ចំណូលសរុប | | ២៨ ៧៦៤ | ១១០ ៦៦៨ | ៦៦ ៩៧៤ |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (៣ ០៣៣) | ៨ ២០៧ | ១ ៩៤៥ |
| ចំណេញប្រតិបត្តិការ | | ២ ៤៩៩ | ១០ ៩០៩ | ៩ ១២៨ |
| (ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | (៣ ៥៧៤) | ៦ ៧១២ | ៩៨៧ |
| ចំណេញ/(ខាត)សរុបលម្អិត | | ១៨៣ | ៦ ២៥៨ | (៧៤៧) |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទីបួន ឆ្នាំ ២០២២** | **ឆ្នាំ ២០២១** | **ឆ្នាំ ២០២០** |
| អនុបាតសាធនភាព | | (០,៦០%) | ២,៤០% | ៧,៤៣% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ)* | | (៥,៧១%) | ៤៩,៩៣% | ២០៣,៨៧% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៩៣ | ០,៩០ | ០,២៨ |
| | អនុបាតចរន្តលឿន | ០,៩២ | ០,៨៨ | ០,២៤ |
| | | **ត្រីមាសទីបួន ឆ្នាំ ២០២២** | **ត្រីមាសទីបួន ឆ្នាំ ២០២១** | **ត្រីមាសទីបួន ឆ្នាំ ២០២០** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | (០,៣០%) | ០,៥៨% | ០,១០% |
| | អនុបាតចំណេញធៀបនឹងមូលធន | (៣,២៥%) | ៧,១៥% | ១,៤១% |
| | អនុបាតគម្លាតចំណេញដុល | ២៤,៣៣% | ១៣,១៤% | ២១,៩៦% |
| | អនុបាតគម្លាតចំណេញភាព | (១២,៤៣%) | ៦,០៦% | ១,៤៧% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) (រៀល) | (៤៧,៦៩) | ៨៥,៣១ | ១៣,៧៩ |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | ០,៣០ | ១,៩១ | ១,១៨ |

PESTECH

| | | | |
|---|---|---|---|
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ប្រសិនមាន) (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | គ្មាន | គ្មាន | គ្មាន |

* កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ៤៣ ៨៧៩ លានរៀល (ឆ្នាំ ២០២១៖ ២០ ៥៥៤ លានរៀល) និងកម្ចីរយៈពេលវែង មានចំនួន ៣៧២ ៦៩៤ លានរៀល គិតត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២ (ឆ្នាំ២០២១៖ ៤០៧ ៨០៦ លានរៀល) ។

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



PESTECH

# សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុននិកជាទីរាប់អាន!

ក្នុងអំឡុងពេលការិយបរិច្ឆេទបញ្ចប់ឆ្នាំហិរញ្ញវត្ថុ២០២២នេះបានស្ដែងចេញនូវសកម្មភាពទីផ្សាររបស់វិនិយោគិនដែលមានសភាពស្ងប់ស្ងាត់ដោយសារសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដោយមានការកើនឡើងឥតឈប់ឈរនៃអត្រាការប្រាក់ និងការបន្តស្ថានភាពបិទខ្ទប់នៅក្នុងប្រទេសចិន។

ភាពមិនប្រាកដប្រជាទូទាំងសកលបានផ្ដល់ផលប៉ះពាល់ដែលមិនបានគ្រោងទុកដល់ដំណើរការដឹកជញ្ជូន ការគ្រប់គ្រងខ្សែចង្វាក់ផ្គត់ផ្គង់ ការប្រែប្រួលមិនសមស្របនៃថ្លៃទំនិញ និងវត្ថុធាតុដើម និងការលេចឡើងនូវចំណាយលើហិរញ្ញប្បទាន។ កត្តាទាំងនេះជំរុញឱ្យមាននូវបញ្ហាប្រឈមដែលមិនបានគ្រោងទុកចំពោះក្រុមហ៊ុន ក្នុងការអនុវត្តគម្រោង និងប្រតិបត្តិការរបស់ក្រុមហ៊ុន។ ដូចនេះ យើងសង្កេតឃើញការធ្លាក់ចុះនៃប្រតិបត្តិការហិរញ្ញវត្ថុទូទៅ ដូចដែលបានបញ្ជាក់នៅក្នុងឆ្នាំហិរញ្ញវត្ថុ២០២២។ ទោះបីជាយើងបានទប់ស្កាត់នូវផលប៉ះពាល់នេះយ៉ាងមានប្រសិទ្ធភាពយ៉ាងណា ក៏គណៈគ្រប់គ្រងយើងជឿជាក់ថាផលប៉ះពាល់អវិជ្ជមានទាំងនេះជាធម្មតាមានការប្រែប្រួល និងអាចទប់ស្កាត់បាននាអំឡុងឆ្នាំហិរញ្ញវត្ថុនពេលខាងមុខ។

នាស្ថានការណ៍ដែលកំពុងច្របូកច្របល់ថ្មីៗនេះក្រុមហ៊ុនត្រូវរក្សាឱ្យបាននូវដំណើរការនៃការអភិវឌ្ឍក្រុមហ៊ុន ហេដ្ឋារចនាសម្ព័ន្ធថាមពលនៃកម្ពុជាដែលត្រៀមរួចជាស្រេចក្នុងការផ្គត់ផ្គង់ថាមពលដល់តំបន់មេគង្គដ៏ធំមួយនេះ តាមរយៈកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ធុរកិច្ចរយៈពេលវែងប្រកបដោយចីរភាព។ យើងត្រូវបន្តបណ្ដុះបណ្ដាលចំណេះដឹងដល់បុគ្គលមានទេពកោសល្យនៅកម្ពុជា វិស្វករ អ្នកជំនាញស្ថាបត្យកម្ម ក្រុមការងារថែទាំ និងប្រតិបត្តិការដែលមានជំនាញ និងលើកកម្ពស់ដល់ការបន្តការយល់ដឹងផ្នែកឧស្សាហកម្មសំខាន់ៗដើម្បីធានានូវការបន្តកសាងសមត្ថភាពសម្រាប់ក្រុមហ៊ុន។

យើងសូមអះអាងចំពោះភាគហ៊ុនិក អតិថិជន អ្នកផ្គត់ផ្គង់ និងភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ថាការលះបង់ និងភាពអត់ធ្មត់បំផុតរបស់យើងនឹងនាំមកនូវការសម្រេចឱ្យបាននូវគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថាមពលដែលអាចទុកចិត្តបាន និងការប្ដេជ្ញាប្រឹងប្រែងសម្រេចនូវកំណើននិរន្តនៅក្នុងរយៈពេលវែង។

សូមអរគុណ

Paul Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ

កាលបរិច្ឆេទៈ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០២២

PESTECH

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

ភាគហ៊ុនិកជាទីរាប់អាន!

ត្រីមាសទី៤ នៃឆ្នាំហិរញ្ញវត្ថុ ២០២២ បានបញ្ជាក់ពីការធ្លាក់ចុះនៃចំណូលជាមធ្យមដែលជាលទ្ធផល នៃឥទ្ធិពលស្ថានភាពមិនច្បាស់លាស់នៃការជាប់គាំងម៉ាក្រូសេដ្ឋកិច្ចនិងភូមិសាស្ត្រនយោបាយដូច ដែលលោកប្រធានក្រុមប្រឹក្សាភិបាលបានមានប្រសាសន៍នៅក្នុងសេចក្តីថ្លែងរបស់លោកប្រធាន។

ទោះបីជាយើងជួបប្រឈមបញ្ហាទាំងនេះ ក៏ក្រុមការងារអនុវត្តគម្រោង និងប្រតិបត្តិការនៅតែខិតខំ ប្រឹងប្រែងឥតឈប់ឈរក្នុងការអនុវត្តតួនាទីដើម្បីសម្រេចបាននូវប្រតិបត្តិការពាណិជ្ជកម្ម និងការ បញ្ចប់គម្រោងចុងក្រោយរបស់យើង (COD) គឺ គម្រោងថាមពលពន្លឺព្រះអាទិត្យខ្នាតធំ Surya នៅ ក្រុងបាវិត ខេត្តស្វាយរៀង។ តាមរយៈសមិទ្ធផលទាំងនេះ យើងបានផ្គត់ផ្គង់បណ្តាញថាមពល បៃតងប្រកបដោយនិរន្តរភាពដល់បណ្តាលអគ្គិសនីនៅកម្ពុជា ដើម្បីជួយកាត់បន្ថយការកើនឡើង នៃកាបូនទាំងមូលសម្រាប់ប្រជាជាតិ នៅក្នុងរយៈពេល ២០ឆ្នាំខាងមុខ។

មួយវិញទៀត យើងបានដាក់ឱ្យដំណើរការឱ្យអស់លទ្ធភាពនូវគម្រោងខ្សែបញ្ជូនថាមពល ២៣០គីឡូវ៉ាត់ ពីអនុស្ថានីយទិសបូព៌ានៃក្រុងសៀមរាបទៅខេត្តឧត្តរមានជ័យ ដែលគម្រោងនេះបញ្ចប់បានជាង ៩៥% នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។ យើងកំពុងឈានទៅដល់ការសម្រេចទៅតាមកាល បរិច្ឆេទកំណត់នៃគម្រោងប្រតិបត្តិការពាណិជ្ជកម្មដែលអាចបន្រហូតដល់ខែធ្នូ ឆ្នាំ២០២២។ គម្រោងនេះឆ្លងកាត់តំបន់ដែលមានប្រជាជនរស់នៅក្នុងក្រុងសៀមរាប ដូច្នេះតម្រូវឱ្យមានការពិនិ ត្យបន្ថែមនៅពេលអនុវត្តគម្រោង ចាប់ពីការរៀបចំបង្គោលអគ្គិសនីពិសេស សកម្មភាពចាក់បុកគ្រឹះ បង្គោល និងភាពរំញ័រ។ ជាលទ្ធផល ដំណាក់កាលចុងក្រោយនៃគម្រោងនេះត្រូវដំណើរការយឺតៗ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអតិបរមាដល់សហគមន៍នៅក្នុងតំបន់នោះ។

តាមរយៈគោលដៅរយៈពេលវែងក្នុងការបង្កើនលំហូរប្រាក់ចំណូលកើតមានសម្រាប់ក្រុមហ៊ុន ការ ថែទាំ និងប្រតិបត្តិការទាំងមូលរបស់យើង (O&M) មានកិច្ចសន្យាសម្រាប់ប្រព័ន្ធខ្សែបញ្ជូន ហើយ គ្រឿងបរិក្ខារផលិតថាមពលកែច្នៃមានសមត្ថភាពរកចំណូលបានប្រមាណ ៣.៣លានដុល្លាអាមេរិក ក្នុងមួយឆ្នាំ។ នាពេលខាងមុខ យើងរំពឹងថាកំណើនថេរនៃផ្នែក O&M ជួយបង្កើតប្រភពចំណូលនិរន្ត សម្រាប់ក្រុមហ៊ុន។

យើងបានបន្តការធ្វើកិច្ចលទ្ធកម្មលើកិច្ចការថ្មីៗយ៉ាងសកម្ម តាមរយៈការចូលរួមការធ្វើដេញថ្លៃជា ច្រើននៅកម្ពុជា។ យើងនឹងក្លាយជាក្រុមហ៊ុនខ្នាតធំឆ្នើមបំផុតខាងផ្នែកគម្រោងផលិតថាមពលពន្លឺ ព្រះអាទិត្យនៅក្នុងតំបន់ តាមរយៈការចូលរួមជាមួយក្រុមហ៊ុនពហុជាតិល្បីៗ ដើម្បីលើកកម្ពស់ ដំណោះស្រាយថាមពលបៃតងទៅអតិថិជននៅគ្រប់វិស័យទូទាំងកម្ពុជា។

យើងប្រកាន់ភ្ជាប់ទស្សនៈវិជ្ជមានលើលទ្ធផលអាជីវកម្មនាពេលអនាគតរបស់ក្រុមហ៊ុន និងសូម ឆ្លៀតឱកាសនេះថ្លែងអំណរគុណដល់ភាគហ៊ុនិកអតិថិជនអ្នកផ្គត់ផ្គង់និងដៃគូអភិវឌ្ឍន៍របស់ផេសថិក ដែលតែងតែគាំទ្រ និងមានទំនុកចិត្តលើដំណើរអភិវឌ្ឍន៍របស់យើង។

PESTECH

សូមអរគុណ

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

Han Fatt Juan

ប្រធាននាយកប្រតិបត្តិ

កាលបរិច្ឆេទ៖ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០២២

PESTECH

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប .................... i
សមាសភាពក្រុមប្រឹក្សាភិបាល .................... ii
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល .................... iii
សេចក្តីថ្លែងរបស់នាយប្រតិបត្តិ .................... iv

**ផ្នែកទី ១-ព័ត៌មានទូទៅនៃក្រុមហ៊ុនចុះបញ្ជី**

ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី

ខ. ប្រភេទអាជីវកម្ម

គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច

ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ**

**ផ្នែកទី ៤ - កិច្ចពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល

ឃ.ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ

ង. ផលប៉ះពាល់នៃអតិផរណា

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងសាច់ប្រាក់របស់រាជរដ្ឋាភិបាល

**ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន (ប្រសិនបើមាន)**

ហត្ថលេខារបស់អភិបាលក្រុមហ៊ុន

PESTECH

## ផ្នែកទី ១ - ព័ត៌មានទូទៅពាក់ព័ន្ធនឹងក្រុមហ៊ុន

### ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **ផេសថិក (ខេមបូឌា)ម.ក**

ជាអក្សរឡាតាំង៖ **PESTECH (Cambodia) PLC**

លេខកូដស្តង់ដារ៖ **PEPC**

អាសយដ្ឋាន៖ **ជាន់ទី១០, អគារលេខ២៥, ផ្លូវម៉ៅសេទុង, ភូមិ៩, សង្កាត់បឹងកេងកង១, ខណ្ឌបឹងកេងកង, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា។**

លេខទូរសព្ទ៖ **+៨៥៥ ២៣ ៨៨២ ១០៥** ទូរសារ៖ **+៨៥៥ ២៣ ៨៨២ ១០៦**

គេហទំព័រ៖ www.pestech.com.kh អ៊ីមែល៖ **info@pestech.com.my**

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ **00000៩៥៧** កាលបរិច្ឆេទ៖ **ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១០**

លេខអាជ្ញាប័ណ្ណអាជីវកម្ម៖ **៣២៦ Brk.DnS/ASN** ចេញដោយ៖ **MLMUPC**

កាលបរិច្ឆេទ៖ **ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៨**

សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ៖ **១៧១/២០ គ.ម.គ / ស.ស.រ.**

គ.ម.ក កាលបរិច្ឆេទ៖ **២២ ខែកក្កដា ឆ្នាំ២០២០**

អ្នកតំណាងរបស់ក្រុមហ៊ុន៖ **Paul Lim Pay Chuan**

### ខ. ប្រភេទអាជីវកម្ម

PCL ចូលរួមជាចម្បងនៅក្នុងការផ្តល់ដំណោះស្រាយផ្នែកវិស្វកម្ម និងបច្ចេកទេសនៃប្រព័ន្ធអគ្គិសនីគ្រប់ជ្រុងជ្រោយសម្រាប់៖

- ការរចនាប្លង់ ការធ្វើលទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ឲ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គិសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គិសនីក្រោមដី សម្រាប់បញ្ជូន និងចែកចាយអគ្គិសនីផងដែរ
- ការដំណើរការ និងថែទាំ ("O&M") ខ្សែបញ្ជូនអគ្គិសនី និងអនុស្ថានីយ៍ និង
- ការធ្វើជំនួញសមាសធាតុ និងបរិក្ខារប្រព័ន្ធអគ្គិសនីដែលមានពាណិជ្ជសញ្ញាជារបស់ខ្លួនឯង និងមិនមែនជារបស់ខ្លួនឯង។

### គ.ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

ស្ថិតក្រោមការពិនិត្យ មិនមានព្រឹត្តិការណ៍សំខាន់ នៅក្នុងកំឡុងពេលឆមាសនេះទេ ។

## ផ្នែកទី ២ - ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការអាជីវកម្ម

### ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលប្រចាំត្រីមាស ដែលមានទឹកប្រាក់ចំនួន ២៤ ៥៣៣ លានរៀល (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ១០៧ ៤៧៨ លានរៀល) ដែលស្មើនឹងប្រមាណ ៨៥,៣% (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៩៧,១%) នៃចំណូលសរុប។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសកម្មភាពថែទាំ("O&M")ប្រាក់ចំណូល ("O&M")របស់យើងដែលទទួលស្គាល់ផ្អែកលើមូលដ្ឋានប្រចាំត្រីមាស ចំនួន ៣ ៣៤៤ លានរៀល (ប្រហែល ៨២៤ ០០០ ដុល្លារអាមេរិច)ដែលបានរួមចំណែកប្រមាណចំនួន ៤ ២៣១ លានរៀល ឬ ១៤,៧% នៃចំណូលសរុប (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៣ ១៩០ លានរៀល ឬ ២,៩%)។

ក្នុងកំឡុងត្រីមាសនេះ យើងបានទទួលស្គាល់ចំណូលហិរញ្ញប្បទានមានចំនួន ២ ៦៩៥ លានរៀល (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ២០២១៖ ២ ៩៧០ លានរៀល)បានមកពីការអនុលោមតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRS") ១៥ សម្រាប់ទ្រព្យសកម្មកិច្ចសន្យាពីគម្រោងមួយចំនួនរបស់យើង ។

### ខ. រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទីបួន ឆ្នាំ ២០២២ | | ត្រីមាសទីបួន ឆ្នាំ ២០២១ | | ត្រីមាសទីបួន ឆ្នាំ ២០២០ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ("EPCC) កិច្ចសន្យាសម្រាប់បណ្តាញអគ្គិសនីនិងអនុស្ថានីយ៍ | ២៤ ៥៣៣ | ៨៥,៣ | ១០៧ ៤៧៨ | ៩៧,១ | ៦៣ ៧៦៤ | ៩៥,២ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៤ ២៣១ | ១៤,៧ | ៣ ១៩០ | ២,៩ | ៣ ២១០ | ៤,៨ |
| | **ប្រាក់ចំណូលសរុប** | **២៨ ៧៦៤** | **១០០,០** | **១១០ ៦៦៨** | **១០០,០** | **៦៦ ៩៧៤** | **១០០,០** |
| | ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យា | ២ ៦៩៥ | ១០០,០ | ២ ៩៧០ | ១០០,០ | គ្មាន | គ្មាន |
| | **ប្រាក់ចំណូលសរុប** | **៣១ ៤៥៩** | **១០០,០** | **១១៣ ៦៣៨** | **១០០,០** | **៦៦ ៩៧៤** | **១០០,០** |

## ផ្នែកទី ៣ - របាយការណ៍ហិរញ្ញវត្ថុដែលត្រូវធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយដោយសវនករឯករាជ្យ។

PESTECH

## ផ្នែកទី ៤ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ("MD&A")

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ២៨ ៧៦៤ លានរៀល ដោយថយចុះចំនួន ៨១ ៩០៤ លានរៀល ឬ ៧៤,០១% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដែលបានកត់ត្រាត្រឹម ១១០ ៦៦៨ លានរៀល ។ បម្រែបម្រួលនៃប្រាក់ចំណូលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នដែលស្ថិតនៅក្រោមការត្រួតពិនិត្យគឺបណ្តាលមកពីការបញ្ចប់នៃគម្រោងនៅបាវិត ហើយមានការវិវឌ្ឍន៍នៃគម្រោងភាគខាងកើតនៃខេត្តសៀមរាបដែលកំពុងដំណើរការបន្តបន្ទាប់រហូតដល់បញ្ចប់នៃវដ្តគម្រោង។

២. ការវិភាគចំណូលតាមផ្នែក

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ៍ គឺជាកត្តាចូលរួមសំខាន់ចំពោះប្រាក់ចំណូលសម្រាប់របាយការណ៍ប្រចាំត្រីមាសដែលមានទឹកប្រាក់ចំនួន ២៤ ៥៣៣ លានរៀល (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ១០៧ ៤៧៨ លានរៀល)ដែលស្មើនឹងប្រមាណ ៨៥,៣% (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២១៖ ៩៧,១%)នៃចំណូលសរុប ។

ការបំពេញបន្ថែមលើសេវាកម្ម EPCC របស់យើងដែលជាប្រតិបត្តិការ និងសេវាថែទាំ("O&M") ប្រាក់ចំណូល("O&M")របស់យើងដែលទទួលស្គាល់ផ្អែកលើមូលដ្ឋានប្រចាំត្រីមាស ចំនួន ៣ ៣៩៤ លានរៀល (ប្រហែល ៨២៤ ០០០ ដុល្លារអាមេរិច)ដែលស្មើនឹងប្រមាណ ៤ ២៣១ លានរៀល ឬ ១៤,៧%នៃចំណូលសរុប(ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ២០២១៖ ៣ ១៩០ លានរៀលឬ២,៩%) ។

៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ២៤,៣៣% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនមានចំនួន ១៣,១៤% ដោយកើនឡើងចំនួន ១១,១៩%។ សរុបមកប្រាក់ចំណេញសរុបក្នុងរយៈពេលបច្ចុប្បន្នគឺស្ថិតនៅក្រោមការរំពឹងទុករបស់សម្ព័ន្ធក្រុមហ៊ុន។

៤. ការវិភាគចំណេញ/ខាតមុនបង់ពន្ធ

ខាតមុនបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្ន ក្រោមការត្រួតពិនិត្យឡើងវិញ ដែលត្រូវបានកត់ត្រាត្រឹមចំនួន ៣ ០៣៣លានរៀល បើប្រៀបធៀបទៅនឹងការចំណេញមុនពេលបង់ពន្ធមានចំនួន ៨ ២០៧ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះមានចំនួន ១១ ២៤០ លានរៀល ឬ ១៣៧,០% ។ ខាតមុនបង់ពន្ធជាកត្តាចម្បងដែលធ្វើអោយថ្លៃដើមហិរញ្ញប្បទានខ្ពស់ជាងបើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

PESTECH

៥. ការវិភាគចំណេញ/ខាតក្នុងការិយបរិច្ឆេទ

ការខាតក្រោយដកពន្ធនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ៣ ៥៧៤ លានរៀល បើប្រៀបធៀបទៅនឹងចំណេញក្រោយដកពន្ធមានចំនួន ៦ ៧១២ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះមានចំនួន ១០ ២៨៦ លានរៀល ឬ ១៥៣,២% ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយ ដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការចំពោះសម្ព័ន្ធក្រុមហ៊ុនឡើយ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២២ បានកត់ត្រាត្រឹម ២៨ ៧៦៤ លានរៀល ដោយថយចុះចំនួន ៨១ ៩០៤ លានរៀល ឬ ៧៤,០១% ប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន បានកត់ត្រាត្រឹម ១១០ ៦៦៨ លានរៀល ។ បម្រែបម្រួលនៃចំណូលសរុបបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញគឺបណ្តាលមកពីការបញ្ចប់គម្រោងនៅបាវិតហើយមានការវិឌ្ឍន៍នៃគម្រោងភាគខាងកើតនៃខេត្តសៀមរាប ដែលត្រូវបានដំណើរការជាបន្តបន្ទាប់រហូតដល់ការបញ្ចប់នៃវដ្តគម្រោង។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

## ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើងគឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ២០% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ៧,២០% (គិតត្រឹមថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២២ ប្រភពសារព័ត៌មានខ្មែរថាមស៖ *កំណត់ត្រាអតិផរណានៅខែឧសភា ដែលខ្ពស់បំផុតក្នុងទសវត្សរ៍នៅប្រទេសកម្ពុជា)* រងផលប៉ះពាល់ត្រឹមតែ ១,៤៦% ប៉ុណ្ណោះចំពោះប្រាក់ចំណេញរបស់យើង។សម្រាប់រាល់ការចំណាយប្រតិបត្តិការផ្សេងៗទាំងអស់មានសមាសធាតុចំណាយថេរនៅក្នុងរយៈពេលនៃកិច្ចសន្យាទាំងមូល។ ក្រៅពីការលើកឡើងខាងលើនេះពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានាដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុ នៅក្នុងអំឡុងឆ្នាំនេះនោះទេ។

## ផ្នែកទី ៥ - ព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

## ហត្ថលេខារបស់អភិបាលក្រុមហ៊ុន

(នឹងត្រូវបានចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល រឺយ៉ាងតិចដោយប្រធានប្រតិបត្តិចំនួនពីររូប)

កាលបរិច្ឆេទ៖ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០២២

បានអាន និងឯកភាព៖

ហត្ថលេខា

ឈ្មោះ៖ Paul Lim Pay Chuan

មុខតំណែង៖ ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ